អស់លោក ជាគណៈកម្មាធិការដូចក្នុងប្រការ ១ មានភារកិច្ច អនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៣៥ សសរ
## ស្តីពីការបង្កើតគណៈកម្មការរៀបចំពិធីសម្ពោធ និង ដាក់អោយដំណើរការជាផ្លូវការខេត្តឧត្តរមានជ័យ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៥/០៧ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតខេត្តឧត្តរមានជ័យ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មាធិការមួយមានឈ្មោះថា គណៈកម្មការរៀបចំពិធីសម្ពោធ និង ដាក់អោយដំណើរការជាផ្លូវការ ខេត្តឧត្តរមានជ័យ ដែលរួមមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ព្រុំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២-ឯកឧត្តម | ចាយ សាំងយុន | រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាអនុប្រធាន |
| ៣-ឯកឧត្តម | ពេជ ម៉ុនធិន | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ជាសមាជិក |
| ៤-លោក | ម៉ុន សម | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៥-ឯកឧត្តម | ប្រាជ្ញ ចន្ទ | អគ្គនាយករដ្ឋបាលក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៦-ឯកឧត្តម | តេង សាវង្ស | អគ្គនាយករង អគ្គនាយកដ្ឋាននគរបាលជាតិ | ជាសមាជិក |

៧-ឯកឧត្តម ទីវ៉ន ជាតិ អភិបាលខេត្តឧត្តរមានជ័យ ជាសមាជិក

៨-លោក ម៉ៅ នីវ អភិបាលរងទី១ ខេត្តឧត្តរមានជ័យ ជាសមាជិកអចិន្ត្រៃយ៍

៩-លោក ឈាំ នុំ អភិបាលរងទី១ ខេត្តសៀមរាប ជាសមាជិក

១០-លោក នន ស៊ុំ អភិបាលរងទី១ ខេត្តបន្ទាយមានជ័យ ជាសមាជិក

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច :

- សហការជាមួយក្រសួងស្ថាប័ន អាជ្ញាធរខេត្តពាក់ព័ន្ធ ដើម្បីរៀបចំពិធីសម្ពោធ ប្រកាសជាផ្លូវការ ខេត្តឧត្តរមានជ័យឲ្យបានក្នុងអំឡុង ខែ មេសា ឆ្នាំ១៩៩៩ នេះ ។
- សហការជាមួយអាជ្ញាធរ ខេត្តឧត្តរមានជ័យ រៀបចំទីតាំងសាលាខេត្ត សាលាស្រុកសាលាឃុំ និង មូលដ្ឋានគ្រឹះចាំបាច់សំរាប់បំពេញការងារ ។
- សហការជាមួយក្រសួងស្ថាប័ន និង ខេត្តពាក់ព័ន្ធ ផ្ទេរភូមិសាស្ត្រ ចលនទ្រព្យ អចលនទ្រព្យ មន្ត្រីរាជការស៊ីវិល យោធា នគរបាល ឲ្យមកចំណុះខេត្តឧត្តរមានជ័យ ។

**ប្រការ ៣ :** គណៈកម្មការរៀបចំពិធីសម្ពោធប្រកាសជាផ្លូវការ ខេត្តឧត្តរមានជ័យមានសិទ្ធិបង្កើតអនុគណៈកម្មការផ្សេងៗ ទៀតសំរាប់ជំនួយការងារ តាមការចាំបាច់ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័ន និង ខេត្តពាក់ព័ន្ធ និង ឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ១ ខាងលើ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ដោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

***

រាជធានីភ្នំពេញ ,ថ្ងៃទី០៩ ខែមេសា ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ៣៦ សសរ

## ស្តីពីការបង្កើតគណៈកម្មការ សំរាប់ដោះស្រាយ បុគ្គលិក បញ្ហាដីធ្លី នៅខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ

***

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី